**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sports

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

ROYAL UNIVERSITY OF LAW AND ECONOMICS

**មហាវិទ្យាល័យ នីតិសាស្ត្រ**

Faculty of law


# កិច្ចការស្រាវជ្រាវ

*មុខវិជ្ជា:* **ម៉ោងអនុវត្តនីតិរដ្ឋធម្មនុញ្ញ**

(TD Constitution law)

*ប្រធានបទ:*

# អំណាចព្រះមហាក្សត្រ


*ណែនាំដោយ:*

**សាស្ត្រាចារ្យ ស្រ៊ិន សុវណ្ណ**

*ក្រុមស្រាវជ្រាវ:*

- ឡា ក្រឹម
- ក. សំ ស្រីនិត
- សាំង សេដ្ឋាភិរម្យ
- ក. ហែន កន្និការ
- ក. ហុង សុវណ្ណគីរី


ឆ្នាំទី២ (២០១១-២០១២)

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sports
សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS
មហាវិទ្យាល័យ នីតិសាស្ត្រ
Faculty of law

# កិច្ចការស្រាវជ្រាវ

*មុខវិជ្ជា:* **ម៉ោងអនុវត្តនីតិរដ្ឋធម្មនុញ្ញ**

(TD Constitution law)

*ប្រធានបទ:*

## អំណាចព្រះមហាក្សត្រ

*ណែនាំដោយ:*

**សាស្ត្រាចារ្យ ស្រិន សុវណ្ណ**

*ក្រុមស្រាវជ្រាវ:*

- ឡោ ក្រឹម
- ក. សំ ស្រីនិត
- សាំង សេដ្ឋាភិរម្យ
- ក. ហែន កន្និការ
- ក. ហុង សុវណ្ណគីរី

ឆ្នាំទី២ (២០១១-២០១២)

# អារម្ភកថា

ជាកិច្ចបើកទំព័រ យើងខ្ញុំទាំងអស់គ្នា សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូបជាពិសេស សិស្ស-និស្សិត ព្រមទាំងសាស្ត្រាចារ្យជាទីគោរព ។

យើងខ្ញុំទាំងអស់គ្នា ជាក្រុមនិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងរាជធានីភ្នំពេញ បានខិតខំប្រឹងប្រែងរៀបចំនូវកិច្ចការស្រាវជ្រាវនេះ ដោយប្រព្រឹត្តទៅក្រោមការណែនាំ និងបង្ហាត់បង្ហាញដោយផ្ទាល់ពីសំណាក់សាស្ត្រាចារ្យ **ស្រិន សុវណ្ណា** ព្រមទាំងបានផ្តល់ឱកាសអោយយើងខ្ញុំស្រាវជ្រាវប្រធានបទនេះ។

គោលបំណងសំខាន់ក្នុងការស្រាវជ្រាវនេះ គឺចង់ស្វែងយល់អំពីៈ

- អ្វីទៅជាអំណាចរបស់ព្រះមហាក្សត្រ?
- តួនាទី និងភារៈកិច្ចរបស់ព្រះមហាក្សត្រ
- ជាពិសេស ចង់ដឹងថា តើព្រះមហាក្សត្រមានអំណាចដែរ ឬទេ?

ជាទីអវសាននេះ សូមជូនពរដល់អ្នកអានគ្រប់រូបអោយជួបប្រទះតែនឹងភាពសុខដុម្បរមនា រុងរឿង ថ្កុំថ្កើង និងមានសុភមង្គលជានិរន្តន៍កុំបីឃ្លៀងឃ្លាតឡើយ។

ម៉្យាងវិញទៀតយើងខ្ញុំទាំងអស់គ្នាសូមអភ័យទោសផងដែរ ចំពោះកង្វះខាតទាំងឡាយដែលមាននៅការស្រាវជ្រាវនេះ ព្រមជាមួយនោះ យើងខ្ញុំនឹងរងចាំទទួលការរិះគន់ដើម្បីស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្នាគ្រប់វិនាទី។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមករា ឆ្នាំ២០១២

ក្រុមនិស្សិតថ្នាក់ $L_2A_2$

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងអស់គ្នា ដែលជានិស្សិតថ្នាក់បរិញ្ញាប័ត្រនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំដែងនូវកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតៈ

សូមលើកអញ្ជលីលំឱនកាយវាចារចិត្តគោរពដល់លោកអ្នកដ៏មានគុណទាំងពីរមាន មាតាបិតា ដែលបានផ្តល់កំណើតចិញ្ចឹមថ្នាក់ថ្នមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងទំនុកបំរុងគ្រប់បែបយ៉ាងទាំងសម្ភារៈ ទាំងស្មារតី និងថវិកាអោយកូនបានសិក្សារៀនសូត្រចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់មហាវិទ្យាល័យ។

ឯកឧត្តម **យក់ ខ៉ុយ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតអោយយើងខ្ញុំទាំងអស់គ្នាបានចូលរៀននៅសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំថែមទៀតផង។

សាស្ត្រាចារ្យ **ស្រិន សុវណ្ណា** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃនិងដ៏មមាញឹកក្នុងការបង្ហាត់បង្រៀនផ្តល់ការណែនាំ និងផ្តល់ឯកសារសម្រាប់អោយយើងខ្ញុំបានស្រាវជ្រាវ ។

សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញព្រមទាំងទស្សនៈវិទូល្បីៗក្នុងលោកដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវ ពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនៅពេលកន្លងមក។

សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបានអំពីយើងខ្ញុំ ចំពោះឧបការគុណដ៏ធំធេងចំពោះយើងខ្ញុំទាំងអស់គ្នា។ សូមអ្នកទាំងអស់ទទួលបាននូវបរមសុខដ៏បរិបូរណ៍នៅគ្រប់ពេលវេលា។

ជាទីបញ្ចប់នេះ សូមជូនពរដល់ អ្នកមានគុណ លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់អោយជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# មាតិកា


ចំណងជើង ទំព័រ

អារម្ភកថា ..... I

សេចក្តីថ្លែងអំណរគុណ ..... II

## សេចក្តីផ្តើម

### ជំពូក១

### ការជ្រើសរើសព្រះមហាក្សត្រ

១.១.ក្រុមប្រឹក្សារាជសម្បត្តិ ..... ២

១.២.អ្នកដែលមានសិទ្ធិជ្រើសតាំងជាព្រះមហាក្សត្រ ..... ២

### ជំពូក២

### អំណាចព្រះមហាក្សត្រ

២.១. ព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ ..... ៤

២.២.អំណាចគ្រប់គ្រងដឹកនាំប្រទេស ..... ៥

២.៣.អំណាចជាអគ្គមេបញ្ជាការ ..... ៥

២.៤.ការតែងតាំង ដកនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល ..... ៧

២.៥.ការតែងតាំង ដកមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា ..... ៧

២.៦.អំណាចប្រកាសសង្គ្រាម និងអាសន្ន ...................................................... ៨

៣.៧.អំណាចបន្ធូបន្ថយ និងលើកលែងទោសជាទូទៅ ........................................ ១០

២.៨.ប្រទានគ្រឿងឥស្សរិយសថ្នាក់ជាតិ ឋានន្តរស័ក្តិ ឋានៈរបស់ឥស្សរជន និងមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ...................................................................................... ១១

២.៩.អំណាចជំនួបសវនាការជាមួយបណ្តាប្រទេសផ្សេងៗ ................................. ១២

២.១០.អំណាចប្រកាសអោយប្រើ ............................................................ ១២

## ជំពូក៣

## តួនាទីរបស់ព្រះមហាក្សត្រ

៣.១.តួនាទីរបស់ព្រះមហាក្សត្រ ............................................................ ១៥

៣.២.ឋានៈរបស់ព្រះមហាក្សត្រ ............................................................. ១៥

៣.៣.ព្រះមហាក្សត្រជាប្រមុខអង្គតុលាការ ................................................... ១៥

៣.៤.តួនាទីព្រះមហាក្សត្រក្នុងការដឹកនាំប្រទេសជាតិ ........................................ ១៦

៣.៥.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យច្បាប់ .......................................... ១៧

៣.៦.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យសេដ្ឋកិច្ច ....................................... ១៧

៣.៧.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យនយោបាយ .................................... ១៧

## សេចក្តីសន្និដ្ឋាន

ឯកសារយោង

# សេចក្តីផ្តើម

បណ្តាប្រទេសនៅលើពិភពលោក បានងាកមកកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយយល់ឃើញពីការវិវិត្តន៍ និងការប្រព្រឹត្តទៅមានលក្ខណៈល្អប្រសើរក្នុងការដឹកនាំប្រទេស។

យ៉ាងណាមិញសម្រាប់ប្រទេសកម្ពុជាយើងក៏បានប្រកាន់យករបបរាជានិយម ជាពិសេស បន្ទាប់ពីមានការបោះឆ្នោតជាសកលថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាបានបង្កើត រដ្ឋធម្មនុញ្ញមួយដែលក្នុងនោះក៏បានកំណត់ថា "**ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រគ្រងរាជអាស្រ័យរដ្ឋធម្មនុញ្ញ**" ។ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសរាជានិយម ដែលក្នុង នោះព្រះមហាក្សត្រ ទ្រង់គ្រងរាជ ឬដឹកនាំ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ ជាទូទៅ បុគ្គលដែល គ្រងរាជមានឥទ្ធិពលទូលំទូលាយ ប៉ុន្តែអំណាចមានតិចតួចបំផុត នៅពេលដែលបុគ្គលនោះធ្វើ ឬអនុវត្តតាមនយោបាយរាជរដ្ឋាភិបាល។

យើងសង្កេតឃើញថា រាជានិយមខ្មែរមានលក្ខណៈស្រដៀងគ្នានឹងរាជានិយមចក្រភពអង់គ្លេស ថៃ និងជប៉ុន ពោល គឺព្រះមហាក្សត្រ មានអំណាចផ្នែកពិធីការ "ប្រមុខរដ្ឋ" មានន័យថា ព្រះមហាក្សត្រ មានភារកិច្ចដូចជា ទទួលរជនបរទេសនានា ផ្តល់សារតែងតាំងរដ្ឋទូត ឡាយព្រះហស្តលេខា បើកសម័យប្រជុំរដ្ឋសភា នៅក្រោយពេលបោះឆ្នោតជាទូទៅស្នើអោយគណបក្សឈ្នះឆ្នោតបង្កើតរាជរដ្ឋាភិបាល។

ទោះបីជាព្រះមហាក្សត្រ ទ្រង់គ្រងរាជ្យមិនកាន់អំណាចក៏ដោយ ក៏ព្រះអង្គតែងទទួលបាននូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ប្រជារាស្ត្រ និងអាស្រ័យដោយការប្រកាន់យករដ្ឋាភិបាល ចំពោះ បុគ្គលិកលក្ខណៈព្រះមហាក្សត្រ និងស្ថាប័នព្រះមហាក្សត្រ។ ទាំងនេះមិនអាស្រ័យដោយសារ អំណាចមិនដាក់អោយអនុវត្តតាមផ្លូវច្បាប់ឡើយ។

ក្នុងរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរបស់ប្រជារាស្ត្រកម្ពុជាទាំងមូល ប៉ុន្តែព្រះអង្គមិនចូលប្រឡូកដោយផ្ទាល់ក្នុងសកម្មភាពប្រចាំថ្ងៃនៃការចាត់ចែងរដ្ឋាភិបាលទេ ភារកិច្ចគ្រប់គ្រងនេះទុកអោយស្ថាប័នសភា និងរាជរដ្ឋាភិបាល។ តើព្រះមហាក្សត្រ តួនាទីភារកិច្ចអ្វីខ្លះនៅក្នុងសង្គម និងមានអំណាចដែរ ឬទេ?

# ជំពូក១

# ការជ្រើសរើសព្រះមហាក្សត្រ

## ១.១.ក្រុមប្រឹក្សារាជសម្បត្តិ

របបរាជានិយមកម្ពុជាជារបបជ្រើសតាំង មានន័យថាព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមានៈ

| | |
|---|---|
| – ប្រធានព្រឹទ្ធសភា | ជាប្រធាន |
| – ប្រធានរដ្ឋសភា | ជាអនុប្រធានទី១ |
| – នាយករដ្ឋមន្ត្រី | ជាអនុប្រធានទី២ |
| – សម្តេចព្រះសង្ឃរាជគណៈមហានិកាយ | ជាសមាជិក |
| – គណៈធម្មយុត្តិកនិកាយ | ជាសមាជិក |
| – អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា | ជាសមាជិក |
| – អនុប្រធានទី១ និង អនុប្រធានទី២ រដ្ឋសភា | ជាសមាជិក |

ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ក្រោយពីពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត់ ឬចូលនិវត្តន៍ជាក់រាជ្យ ក្រុមប្រឹក្សារាជសម្បត្តិត្រូវជ្រើសរើសព្រះមហាក្សត្រថ្មីនៃព្រះរាជណាចក្រកម្ពុជា។

## ១.២.អ្នកដែលមានសិទ្ធិជ្រើសតាំងជាព្រះមហាក្សត្រ

មានលក្ខខ័ណ្ឌមួយចំនួន ដែលកំណត់នៅក្នុងរដ្ឋធម្មនុញ្ញស្តីពីការជ្រើសរើសព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា១៤ នៃរដ្ឋធម្មនុញ្ញបានដាក់លក្ខខ័ណ្ឌថា "ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសចេញពីសមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច ៣០វស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គឌួង ព្រះមហាក្សត្រនរោត្តម ឬព្រះមហាក្សត្រស៊ីសុវត្ថិ"។ តំណែងព្រះមហាក្សត្រមិនមែនបើកចំហរសម្រាប់មនុស្សគ្រប់រូបឡើយ។ មិនមែនមនុស្សណាក៏ដោយ សុទ្ធតែអាចត្រូវជ្រើសតាំងធ្វើស្តេចនៃព្រះរាជាណាចក្រកម្ពុជា

បានទេ។ អ្នកដែលត្រូវជ្រើសតាំងជាព្រះមហាក្សត្រ ត្រូវតែជាសមាជិកនៃរាជវង្សានុវង្សខ្មែរ និងជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រអង្គណាមួយក្នុងចំណោមបច្ឆាញាតិទាំង **បី** ហើយអ្នកដែលត្រូវជ្រើសតាំងត្រូវតែមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា។ "ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រ ទ្រង់សោយរាជសម្បត្តិ"។ ព្រះរាយានៃព្រះមហាក្សត្រ មានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយកាន់តួនាទីជាប្រមុខរដ្ឋ ឬជាប្រមុខរដ្ឋាភិបាល ឬកាន់តួនាទីរដ្ឋបាល ឬនយោបាយឡើយ។

# ជំពូក២

# អំណាចព្រះមហាក្សត្រ

## ២.១. ព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា។ ប្រមុខរដ្ឋជាអ្នកតំណាងរដ្ឋ។ កាលណាអង្គក្សត្រ ឬព្រះអង្គម្ចាស់ណាមួយត្រូវបានក្រុមប្រឹក្សារាជសម្បត្តិជ្រើសតាំងជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គមានឋានៈជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ជាស្វ័យប្រវត្តិ និងអស់មួយជីវិត។ "ព្រះមហាក្សត្រ ទ្រង់ជាប្រមុខរដ្ឋមួយជីវិត"។ បើតំណែងព្រះប្រមុខរដ្ឋអស់មួយជីវិត ជាព្រះមហាក្សត្រក៏ត្រូវតែមួយជីវិតដែរ។

នៅក្រោមប្រព័ន្ធនយោបាយរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រជាមុខរដ្ឋនិមិត្តរូប និងកាន់តួនាទីជាពិធីតែប៉ុណ្ណោះ។ ជាប្រមុខរដ្ឋ ព្រះអង្គគង់នៅពីលើកំពូលនៃឋានានុក្រមរចនាសម្ព័ន្ធរដ្ឋ និងជានិមិត្តរូបនៃអធិបតេយ្យភាពនៃរដ្ឋ។ តំណែងប្រមុខរដ្ឋគឺជាធាតុដ៏សំខាន់នៃអត្តសញ្ញាណរួមរបស់ប្រជាពលរដ្ឋ និងរដ្ឋ។ ព្រះអង្គតំណាងអោយរដ្ឋ រដ្ឋាភិបាល និងប្រជាពលរដ្ឋ។ កត្តាដែលសំខាន់គឺថា តំណែងនេះជាតំណែងពិធីតែប៉ុណ្ណោះ និងពុំមានអំណាចនយោបាយពិតប្រាកដទាំងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងនៅក្នុងការគ្រប់គ្រង និងដឹកនាំមាគ៌ានយោបាយរដ្ឋ។ ជាគោលការណ៍ប្រមុខរដ្ឋាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ រដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ទាំងស៊ីវិល និងយោធាទាំងអស់ ត្រូវទទួលការតែងតាំងស្ថិតនៅក្រោមអំណាច និងទទួលខុសត្រូវចំពោះប្រមុខរដ្ឋ។ ពួកគេជាទីប្រឹក្សា និងជាអ្នកបម្រើ ឬជាសមាជិកអង្គការកូនចៅនៃប្រមុខរដ្ឋ។

ជាក់ស្តែងប្រមុខរដ្ឋាភិបាល(នាយករដ្ឋមន្ត្រី) សមាជិករដ្ឋាភិបាល និងការិយាធិបតេយ្យ (ស្ថាប័នមន្ត្រីរាជការ) ឯករាជ្យពីប្រមុខរដ្ឋ។ សិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តមាគ៌ានយោបាយរដ្ឋស្ថិតនៅក្នុងដៃប្រមុខរាជរដ្ឋាភិបាល រដ្ឋាភិបាល និងការិយាធិបតេយ្យជាតិ។ ព្រះមហាក្សត្រ ក្នុងតួនាទីជាប្រមុខរដ្ឋទ្រង់ស្ថិតនៅអព្យាក្រឹត្យ គង់នៅពីលើនយោបាយ និងមិនចូលរួមក្នុងនយោបាយលើកលែងតែក្នុងស្ថានការណ៍អាសន្ន។

មានហេតុផលពីរ ដែលព្រះមហាក្សត្រទ្រង់គងនៅលើនយោបាយគឺៈ

- ជានិមិត្តរូប និងជាអត្តសញ្ញាណនៃរដ្ឋ ប្រមុខរដ្ឋជួយរក្សា ឯកភាពនៃរដ្ឋ ដោយស្ថិតនៅអព្យាក្រឹត្យ។ ការដែលព្រះមហាក្សត្រចូលរួមសកម្មភាពនយោបាយ និងលើកទឹកចិត្តកុំអោយមានការបែកបាក់នយោបាយរវាងក្រុម បក្សពួកនៅក្នុងរដ្ឋ។
- រដ្ឋធម្មនុញ្ញដាក់កម្រិត ព្រះមហាក្សត្រ មិនអោយធ្វើនយោបាយ។ "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច"។ ការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពីនយោបាយនៃរដ្ឋដោយប្រមុខរដ្ឋនឹងជាការរំលោភលើរដ្ឋធម្មនុញ្ញ។

## ២.២.អំណាចគ្រប់គ្រងដឹកនាំប្រទេស

តាមសេចក្តីស្នើ របស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខា លើព្រះរាជក្រិត្យ តែងតាំងផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រី ជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូតនិងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។ តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា លើព្រះជក្រិត្យ តែងតាំង ផ្លាស់ប្តូរ រឺដកចៅក្រមផ្នែកយុត្តាធិការ។

## ២.៣.អំណាចជាអគ្គមេបញ្ជាការ

រដ្ឋធម្មនុញ្ញបានថ្វាយព្រះរាជតួនាទី "ព្រះមហាក្សត្រកម្ពុជា ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ"។ ក្នុងព្រះរាជតួនាទីនេះ និងក្នុងឋានៈជាប្រមុខរដ្ឋព្រះមហាក្សត្រមានអំណាចតែងតាំងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទ។ ដូច្នេះមុខងារ "អគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរង" ដែលមានឋានៈ ខ្ពស់ជានាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការរង ក៏ត្រូវតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះមហាក្សត្រដែរ ហើយមិនចាំបាច់មានសំណើរពីនាយករដ្ឋមន្ត្រី ឬគណៈរដ្ឋមន្ត្រីក៏បាន ពីព្រោះទាំងរដ្ឋធម្មនុញ្ញ ទាំងច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ពុំមាននិយាយថា តំណែងនេះត្រូវតែងតាំងតាមសំណើររបស់នាយករដ្ឋមន្ត្រី ឬគណៈរដ្ឋមន្ត្រីឡើយ។ រដ្ឋធម្មនុញ្ញ បានថ្វាយព្រះមហាក្សត្រនូវតួនាទីជាមេញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ និងពិសេសព្រះអង្គម្ចាស់ទ្រង់ជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងព្រះរាជតួនាទីជាប្រមុខរដ្ឋ

និងជាមេបញ្ជាការកំពូល ព្រះមហាក្សត្រទ្រង់មានសិទ្ធិតែងតាំងអគ្គមេបញ្ជាការ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ បានដោយផ្ទាល់ព្រះអង្គ។

ម្យ៉ាងវិញទៀត រដ្ឋធម្មនុញ្ញបានពិពណ៌នាអំពីរបបនយោបាយ និងរចនាសម្ព័ន្ធរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះរាជាណាចក្រ ដែលប្រកាន់យករបបរាជាធិបតេយ្យអាស្រ័យ រដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ក្នុងឋានៈជារដ្ឋប្រជាធិបតេយ្យសេរី កងកម្លាំងយោធាត្រូវស្ថិតនៅជាកម្លាំងអព្យាក្រឹត្យ មិនកាន់បក្សនយោបាយណាមួយឡើយ។ ភារកិច្ចចំបងនៃកងកម្លាំងយោធា គឺការពាររដ្ឋទប់ទល់ការវាយប្រហារពីកម្លាំងទ័ពនៃរដ្ឋដទៃពីការ**វិទ្ធង្ស**[១] នានៅក្នុងផ្ទៃក្នុងរដ្ឋ។ កិច្ចការពារសន្តិសុខរដ្ឋ គឺជាភារកិច្ចការដ៏សំខាន់នៃរដ្ឋអធិបតេយ្យនីមួយៗ ហើយការផ្តល់កិច្ចការពារសន្តិសុខរដ្ឋ គឺជាភារកិច្ចដ៏ធំធេង និងស្មុគស្មាញ។ រដ្ឋាភិបាលប្រើប្រាស់កងកម្លាំងយោធាសម្រាប់តែកិច្ចការពាររដ្ឋតែប៉ុណ្ណោះ។ ព្រះមហាក្សត្រក្នុងឋានៈជាប្រមុខរដ្ឋ ព្រះអង្គទ្រង់ជាអ្នកអព្យាក្រឹត្យ និងគង់នៅពីលើនយោបាយមិនកាន់បក្សនយោបាយណាមួយឡើយ ហើយ "ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃការឯកភាពជាតិ និងនិរន្តរភាពជាតិ"។ ព្រះអង្គទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា"។

ដូច្នេះអគ្គមេបញ្ជាការ និងអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ត្រូវជា "**មនុស្ស**" ដែលព្រះមហាក្សត្រជ្រើសរើសដោយព្រះអង្គឯង ដើម្បីធានាអោយបាននូវអព្យាក្រឹត្យភាពនៃកងកម្លាំងយោធាមិនអោយនៅក្រោមអំណាចផ្ទាល់នៃនាយករដ្ឋមន្ត្រី ដែលតំណាងអោយគណបក្សនយោបាយឈ្នះឆ្នោត។ ក្នុងខណៈពេលដែលអគ្គមេបញ្ជាការ អគ្គមេបញ្ជាការរងជាមនុស្ស "មនុស្ស" របស់នាយករដ្ឋមន្ត្រី ដោយសារនាយករដ្ឋមន្ត្រីជាអ្នកជ្រើសរើសអព្យាក្រឹត្យភាពនៃកងកម្លាំងយោធាពុំមានអំណាចអោយបានពិតប្រាកដឡើយ ដោយព្រះមហាក្សត្រពុំបំពេញព្រះរាជតួនាទីអ្វីបានដែរ ក្នុងឋានៈជាប្រមុខរដ្ឋ និងជាអគ្គមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ ព្រះប្រមុខរដ្ឋ ពុំអាចបំពេញ ព្រះរាជបេសកម្មជាអ្នកធានាឯករាជ្យជាតិ និរន្តន៍ភាពជាតិ បូរណភាពទឹកដី និងអធិបតេយ្យនៃរដ្ឋបានឡើយ។

---

[១] **វិទ្ធង្ស** (ន(. (បា(. (វិតស:-ធង់- នា៉( (វិទ្ធំសន, វិទ្ធំសនាកម្ចាត់ការ (, ការកម្ចាត់បង់, ការកំចោកពោក, ការរម្លំរម្លាយ, ការបំផ្លិចបំផ្លាញ; អំពើបំបះបំបោរដើម្បីរំលំរំលើងរបបគ្រប់គ្រងរដ្ឋ : *ធ្វើវិទ្ធង្សនា, ប្រើកលឧបាយដោយវិទ្ធំសនា* ។ វិទ្ធំសនា

## ២.៤.ការតែងតាំង ដកនាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល

អំណាចមួយ ក្នុងចំណោមអំណាចតែងតាំងសំខាន់បំផុតរបស់ព្រះមហាក្សត្រ គឺការតែងតាំងនាយករដ្ឋមន្ត្រី និងសមាជិកគណៈរដ្ឋមន្ត្រី។ "ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទ ដែលមានចែងក្នុងមាត្រា១១៩ថ្មី"។ មាត្រា ១១៩ថ្មី បញ្ជាក់ពីនីតិវិធីនេះដូចតទៅ "តាមសេចក្ដីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតអោយបង្កើតរដ្ឋាភិបាល។ វរជន ដែលត្រូវបានចាត់តាំងនេះនាំសហការី ដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួវផ្គងអោយកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ នោះព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល"។

ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី បញ្ជាក់ទៀតថា "សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានសេចក្ដីអនុម័តទុកចិត្តពីរដ្ឋភា"។ ច្បាប់នេះបន្ថែមទៀតថា "អនុរដ្ឋលេខាធិការ ដែលមិនមែនជាសមាជិករាជរដ្ឋាភិបាល និងមិនមែនជាមន្ត្រីជាន់ខ្ពស់រដ្ឋបាលអចិន្ត្រៃយ៍ ក៏ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យដែរ តាមសំណើររបស់នាយករដ្ឋមន្ត្រី"។ ជាមួយនឹងអំណាចតែងតាំង ព្រះមហាក្សត្រទ្រង់ក៏មានអំណាចដកហូតតំណែងនាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល ឬក៏រដ្ឋាភិបាលទាំងមូលតែងម្ដង់ ក្រោយពីរដ្ឋសភាបោះឆ្នោតសម្ដែងសេចក្ដីមិនទុកចិត្តមក។

## ២.៥.ការតែងតាំង ដកមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា

ក្រៅពីអំណាចតែងតាំង និងដកហូតតំណែងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់នៅមានអំណាចតែងតាំងដកហូតមួយទៀតដែលសំខាន់ សម្រាប់ព្រះរាជបេសកកម្មរបស់ព្រះអង្គក្នុងឋានៈជាប្រមុខរដ្ឋ។ រដ្ឋធម្មនុញ្ញថ្វាយព្រះអង្គនូវអំណាចតែងតាំង និងដកហូតមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល និងយោធា។ "តាមសេចក្ដីស្នើ របស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ច មន្ត្រីជាន់ខ្ពស់ស៊ីវិល យោធា ឯកអគ្គរាជទូត និងប្រេសិតវិសមញ្ញនិងពេញសមត្ថភាព។ តាមសេចក្ដីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬដកចៅក្រមផ្ទែក

យុត្តាធិការ"។ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បញ្ជាក់ពីប្រភេទមន្ត្រីរាជការជាន់ខ្ពស់ទាំងស៊ីវិល និងយោធា ដែលត្រូវតែងតាំងដោយព្រះមហាក្សត្រ។ នាយករដ្ឋមន្ត្រីលើកសំណើរថ្វាយ ព្រះមហាក្សត្រតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដូចតទៅៈ

- ទេសាភិបាល ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
- ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង
- ប្រតិភូរាជរដ្ឋាភិបាល
- អភិបាលរាជធានី/ខេត្ត
- ឯកអគ្គរាជទូត
- ប្រេសិវិសាមញ្ញ និងពេញសមត្ថភាព
- នាយអគ្គសេនាធិការ និងនាយអគ្គសេនាធិការរង
- ឧត្តមសេនីយ៍ឡើងទៅ។

មុខងារ និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាមួយចំនួនផ្សេងទៀត ក៏នឹងត្រូវបានតែងតាំងផ្លាស់ប្តូបញ្ចប់ដោយព្រះរាជក្រឹត្យដែរ តាមការកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ដែលបង្កើតដោយស្ថាប័ននោះ។ ដូច្នេះមាត្រា ១៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បញ្ជាក់បន្ថែមលើមាត្រា២១ នៃរដ្ឋធម្មនុញ្ញ អំពីប្រភេទមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដែលត្រូវបានតែងតាំង ផ្លាស់ប្តូរបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ។ ក្រៅពីប្រភេទនេះ គេមិនអាចធ្វើព្រះរាជក្រឹត្យបានឡើយ ហើយមិនមានគ្រប់តែមន្ត្រីជាន់ខ្ពស់ ស៊ីវិល និងយោធា សុទ្ធតែត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យទាំងអស់នោះទេ។

## ២.៦.អំណាចប្រកាសសង្គ្រាម និងអាសន្ន

រដ្ឋធម្មនុញ្ញបានថ្វាយព្រះមហាក្សត្រនូវព្រះរាជតួនាទីជាប្រមុខរដ្ឋ។ ក្នុងព្រះរាជតួនាទីនេះ ព្រះមហាក្សត្រទ្រង់មានព្រះរាជអំណាចប្រកាសអាសន្ន និងប្រកាសសង្គ្រាមក្នុងកាលៈទេសៈចាំបាច់។ មាត្រា២២ថ្មី ចែងថា "នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់

ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា"។ មាត្រា២៤ថ្មី វាក្យខ័ណ្ឌទី២ បន្ថែមទៀតថា "ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា"។

អំណាចរបស់ព្រះមហាក្សត្រ ដែលចែងនៅក្នុងមាត្រា២២ និង២៤ ខាងលើក៏ដូចជាអំណាចព្រះមហាក្សត្រនៅក្នុងមាត្រា២១និង១១៩ថ្មី ដែរ នៅក្នុងមាត្រាទាំងអស់ខាងលើនេះ ព្រះមហាក្សត្រឥតមានសិទ្ធិប្រើអំណាចទាំងនេះ តែអង្គឯងបានទេ។ ព្រះមហាក្សត្រ អាចប្រើអំណាចទាំងនេះបានលុះត្រាណាតែមានការចូលរួមសម្រេចពីស្ថាប័នផ្សេងៗទៀត អង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ។ ស្ថាប័នទាំងនេះ មានអំណាចពិតប្រាកដ រីឯព្រះមហាក្សត្រគ្រាន់តែផ្ដល់ភាពស្របច្បាប់ប៉ុណ្ណោះ ក្នុងក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ព្រះមហាក្សត្រ មិនកាន់អំណាច"។ ក្នុងរឿងអំណាចតែងតាំងច្បាប់ និយាយថា ព្រះមហាក្សត្របំពេញព្រះរាជកិច្ចតាមសំណើររបស់ស្ថាប័នទាំងនេះ។ អំណាចរបស់ព្រះមហាក្សត្រក្នុងការប្រកាសដាក់ប្រទេសជាតិក្នុងភាពអាសន្ន និងសង្គ្រាមក៏ដូច្នេះដែរ ត្រូវធ្វើឡើងក្រោយពីមានការឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ ពាក្យ "តាមសេចក្ដីស្នើរបស់" នៅក្នុងមាត្រា២១ មានន័យថា ព្រះមហាក្សត្រ ឥតមានជំរើសក្រៅពីបំពេញព្រះរាជសកម្មភាពតាមតែគណៈរដ្ឋមន្ត្រី និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយពាក្យថា "ក្រោយពីបានមិនឯកភាពពី" នៅក្នុងមាត្រា២២ មានន័យថា "ព្រះមហាក្សត្រ ទ្រង់បំពេញព្រះរាជកិច្ចនេះទៅបាន លុះណាតែនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា យល់ព្រម។ ព្រះអង្គឥតមានអំណាចសម្រេចស្វ័យតឡើយ"។ បើជាស្ថាប័នទាំងនេះ មិនស្នើព្រះមហាក្សត្រ មិនអាចតែងតាំងបានទេ។ ក៏ដូចគ្នាអញ្ចឹងដែរ បើសិនស្ថាប័នទាំងពីរខាងលើមិនយល់ព្រម ព្រះមហាក្សត្រទ្រង់មិនអាចប្រកាស ដាក់ប្រទេសជាតិក្នុងភាពអាសន្ន និងប្រកាសសង្គ្រាមបានទេ។ ដូច្នេះស្ថាប័នទាំងនេះកំពូលនៅពីលើព្រះមហាក្សត្រទៅទៀត នៅក្នុងក្របខ័ណ្ឌនៃអំណាចនយោបាយ។

តាមមាត្រា២៤ ចង់បញ្ជាក់ថា ព្រះមហាក្សត្រត្រូវតែប្រកាសសង្គ្រាម បើសិនរដ្ឋសភាបានធ្វើការអនុម័តលើសេចក្ដីសម្រេចចិត្តបែបនេះ។ ព្រះមហាក្សត្រគ្រាន់តែសច្ចានុម័តលើសេចក្ដីសម្រេចចិត្តរបស់រដ្ឋសភាតែប៉ុណ្ណោះ ហើយដូចគ្នានឹងរឿងតែងតាំងដែរ ព្រះមហាក្សត្រមិនមែនជាផ្នែកពិតប្រាកដនៃដំណើរការធ្វើសេចក្ដីសម្រេចចិត្តទេ។

សរុបសេចក្ដីមកយើងនិយាយបានថាៈ

- ព្រះមហាក្សត្រមានអំណាចប្រកាសសង្គ្រាម ប៉ុន្តែសេចក្តីប្រកាសនេះ អាចធ្វើទៅបានលុះត្រារដ្ឋសភាអនុម័តរួចហើយ។
- ព្រះមហាក្សត្រ មានអំណាចប្រកាសដាក់ប្រទេសជាតិឋិតក្នុងភាពអាសន្ន ប៉ុន្តែលុះត្រាតែមានការឯកភាពយល់ព្រមពីប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី។

នៅក្នុងករណីនៃការប្រកាសសង្គ្រាម ការប្រកាសដាក់ប្រទេសជាតិក្នុងភាពអាសន្ន រដ្ឋធម្មនុញ្ញតម្រូវព្រះមហាក្សត្រផ្តល់សច្ចានុម័តលើអ្វីដែលរដ្ឋសភា ឬនាយករដ្ឋមន្ត្រីបានសម្រេចអនុម័តរួចហើយ។ ព្រះមហាក្សត្រ ពុំមានអំណាចប្រើសិទ្ធិជំទាស់ទេ បើសិនជាព្រះអង្គមិនសព្វព្រះរាជហឫទ័យលើការអនុម័តនោះ។ ព្រះមហាក្សត្រត្រូវតែឡាយព្រះហស្តលេខាអនុម័ត បើទោះបីព្រះអង្គមិនពេញព្រះទ័យក៏ដោយ។

## ៣.៧.អំណាចបន្ធូបន្ថយ និងលើកលែងទោសជានូនៅ

គ្រប់អំណាចទាំងអស់របស់ព្រះមហាក្សត្រ មានទិដ្ឋភាពរួមមួយ។ ទិដ្ឋភាពរួមនោះ គឺថាអំណាចទាំងនោះ សុទ្ធតែតម្រូវអោយមានការអនុម័តយល់ព្រម ឬការចូលរួមពីស្ថាប័នដទៃទៀត ដូចជាអង្គការនីតិបញ្ញត្តិ អង្គកានីតិប្រតិបត្តិ ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទើបព្រះមហាក្សត្រអាចបំពេញព្រះរាជកិច្ចបាន។ នីតិវិធីនេះស្របទៅតាម គោលការណ៍ដែលថា "ព្រះមហាក្សត្រសោយរាជ ប៉ុន្តែទ្រង់មិនកាន់អំណាច"។

ទោះយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញបានថ្វាយព្រះមហាក្សត្រនូវព្រះរាជសិទ្ធិអំណាចយ៉ាងច្បាស់លាស់ និងពិតប្រាកដក្នុងព្រះរាជកិច្ច ដោយឯករាជ្យលើការលើកលែងទោស។ មាត្រា២៧ និយាយថា "ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"។

នៅពេលព្រះមហាក្សត្រ បានធ្វើការលើកលែងទោសដល់ជនណាមួយ ដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តខុសច្បាប់នៃរដ្ឋ អ្នកប្រព្រឹត្តបទល្មើសនោះ មិនអាចត្រូវបានគេដាក់ទណ្ឌកម្មបានឡើយ ទណ្ឌកម្មត្រូវបានបន្ថយ។

ព្រះមហាក្សត្រ ទ្រង់មានអំណាចលើកលែងទោសដល់សមាជិកទាំងអស់នៃរដ្ឋ ដោយមិនប្រកាន់ពណ៌សម្បុរ នយោបាយក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋ។ រដ្ឋធម្មនុញ្ញមិនបានតម្រូវអោយមានការអនុម័តយល់ព្រមពីអង្គកាន់អំណាចជាមុនឡើយ ដូចជានាយករដ្ឋមន្ត្រី រដ្ឋសភា អង្គនីតិប្រតិបត្តិ

ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ អំណាចលើកលែងទោសរបស់ព្រះមហាក្សត្រ មិនត្រូវបានកម្រិតដោយរដ្ឋធម្មនុញ្ញទេ។

ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូបន្ថយទោស និងលើកលែងទោសជាទូទៅ។ ចំពោះទណ្ឌិតត្រូវបានបន្ធូបន្ថយ និងលើកលែងទោសនេះលុះត្រាតែពួកគាត់មានលក្ខខ័ណ្ឌ ពីរ យ៉ាង:

- អនុវត្តទោសបាន ២/៣(ពីរភាគបី)នៃទោសសរុប
- មានការកែប្រែខ្លួន ឬក៏រៀងចាល។

ការបន្ធូបន្ថយ និងលើកលែងទោសនេះ ធ្វើឡើងក្នុងពិធីបុណ្យ បី គឺ:

- ពិធីបុណ្យ ចូលឆ្នាំប្រពៃណីខ្មែរ
- ពិធីបុណ្យ ពិសាខបូជា
- ពិធីបុណ្យ ចម្រើនព្រះជន្មព្រះមហាក្សត្រ។

ការបន្ធូបន្ថយ និងលើកលែងទោសនេះ ធ្វើបានតែមួយលើកក្នុងមួយឆ្នាំប៉ុណ្ណោះចំពោះទណ្ឌិតម្នាក់។

## ២.៨.ប្រទានគ្រឿងឥស្សរិយសថ្នាក់ជាតិ ឋានន្តរស័ក្តិ ឋានៈរបស់ឥស្សរជន និងមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា

រដ្ឋធម្មនុញ្ញ ក៏បានថ្វាយព្រះមហាក្សត្រនូវអំណាចប្រទានគ្រឿងឥស្សរិយសថ្នាក់ជាតិ និងឋានន្តរស័ក្តិ ឋានៈ ដល់វរជន ឥស្សរជន និងមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ក្នុងខណៈព្រះអង្គជាប្រមុខរដ្ឋ។ មាត្រា ២៩ ចែងថា "ព្រះមហាក្សត្រ ទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយសជាតិ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ ព្រះមហាក្សត្រ ទ្រង់សម្រេចប្រទានឋានន្តរស័ក្តិ ឋានៈយោធា និងស៊ីវិល តាមច្បាប់កំណត់"។

តាមមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញនេះ មានតែងព្រះមហាក្សត្រទេ មានអំណាចអោយរង្វាន់ក្នុងទម្រង់ជាការប្រទាន ឋានៈបុណ្យស័ក្តិដល់អ្នកដែលមានគុណបំណាច់ និងគុណសម្បត្តិចំពោះរដ្ឋ និងរាជបល្ល័ង្ក។ ដូចជាគោរមងារ "**សម្តេច និង ឧញ៉ា**" ជាឋានៈដែលមានតែព្រះមហាក្សត្រទេ មានសិទ្ធិផ្តល់អោយតាមប្រពៃណីរបស់ក្សត្រខ្មែរ និងតាមស្មារតីនៃរដ្ឋធម្មនុញ្ញ"។ "**សម្តេច**" ជាងារខ្ពស់

ជាងគេបំផុតក្នុងឋានានុក្រមស័ក្តិ ក្នុងថ្នាក់មន្ត្រីរាជការជាន់ខ្ពស់ ឥស្សរជន នយោបាយ និងមន្ត្រីសង្ឃជាន់ ខ្ពស់។ ព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យ តែងតាំងប្រទានអោយតាមគុណសម្បត្តិ និងគុណបំណាច់ដ៏ធំធេង ដែលមន្ត្រីរាជការជាន់ខ្ពស់ ឥស្សរជននយោបាយ និងមន្ត្រីសង្ឃជាន់ខ្ពស់មានចំពោះរដ្ឋ ចំពោះព្រះពុទ្ធសាសនា និងរាជបល្ល័ង្ក ក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋ។ រីឯងារ "**ឧកញ៉ា**" ជាងារសម្រាប់ផ្តល់ជាឋានៈដល់ពួកមន្ត្រីជាន់ខ្ពស់ ឬឥស្សរជននយោបាយ។ ព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យតែងតាំងអោយងារជា "ឧកញ៉ា" ដល់មន្ត្រីជាន់ខ្ពស់ ឬឥស្សរជននយោបាយ ដែលមានគុណបំណាច់ចំពោះជាតិ និងរាជបល្ល័ង្ក។

ដូច្នេះ យោងតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងលើមូលដ្ឋានជាក់ស្តែង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជឋានៈជាប្រមុខរដ្ឋ ព្រះអង្គមានអំណាចចាត់តាំងតែងតាំងប្រទានឋានន្តរស័ក្តិឋានៈ និងគ្រឿងឥស្សរិយយលដល់វរជន ឥស្សរជន និងមន្ត្រីជាន់ខ្ពស់នៃរដ្ឋ។ អំណាចនេះ ជាប្រភេទនៃអំណាចអោយរង្វាន់ ដែលជាប្រភពដ៏សំខាន់នៃអំណាចជាមូលដ្ឋានរបស់ព្រះមហាក្សត្រ។ ការកាន់កាប់អំណាចនេះ ធ្វើអោយព្រះមហាក្សត្រស្ថិតក្នុងតំណែងដ៏មានឥទ្ធិពល និងអំណាចនៅក្នុងរដ្ឋ។ ជាពិសេសជាងនេះទៅទៀត ព្រះមហាក្សត្រ ទ្រង់កាន់កាប់អំណាចនេះ ជាការស្របទៅតាមនីតិវិធីច្បាប់ក្នុងព្រះរាជឋានៈ ព្រះអង្គជាប្រមុខរដ្ឋ។

## ២.៩.អំណាចជំនួបសន្ទនាការជាមួយបណ្តាប្រទេសផ្សេងៗ

ព្រះមហាក្សត្រទ្រង់ ទទួលសាតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា។ ជាពិសេស ទ្រង់ទទួលនូវជំនួបសវនាការជាមួយមន្ត្រីជាន់ខ្ពស់ធំៗ ដែលមកបំពេញភារកិច្ចក្នុងគោលបំណងមិត្តភាព និងទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

## ២.១០.អំណាចប្រកាសអោយប្រើ

អំណាចមួយទៀតក្នុងចំណោមអំណាចដ៏សំខាន់ៗបំផុតរបស់ព្រះមហាក្សត្រ គឺឡាយព្រះហស្តលេខាប្រកាសអោយប្រើប្រាស់។ រដ្ឋធម្មនុញ្ញ បានថ្វាយអំណាចនេះអោយព្រះមហាក្សត្រក្នុងព្រះរាជឋានៈរបស់ព្រះអង្គ ជាប្រមុខរបស់រដ្ឋ។ មាត្រា២៨ នៃរដ្ឋធម្មនុញ្ញបានចែងថា "ព្រះមហា

ក្សត្រ ទ្រង់ឡាយព្រះហស្ថលេខា លើព្រះរាជក្រមប្រកាសអោយប្រើរដ្ឋធម្មនុញ្ញ ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និងទ្រង់ឡាយព្រះហស្ថលេខា លើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី"។ មាត្រា៩៣ថ្មី បញ្ជាក់បន្ថែមទៀតថា "ច្បាប់ដែលរដ្ឋសភា បានអនុម័ត និងព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខា ប្រកាសអោយប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ រយៈពេល១០ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសអោយប្រើ។ ប៉ុន្តែបើច្បាប់នេះ បានចែងថាជាការប្រញាប់ច្បាប់នេះ ត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសអោយប្រើ។ ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្ថលេខាប្រកាសអោយប្រើត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសអោយទាន់តាមពេលកំណត់ខាងលើ។

ច្បាប់ដែលប្រកាសដោយប្រមុខរដ្ឋមានសុពលភាព និងកម្លាំងគតិយុត្តនៅក្នុងរដ្ឋទាំងមូល ហើយដែលសមាជិកទាំងឡាយនៃរដ្ឋ(ប្រជាពលរដ្ឋ) ត្រូវគោរពប្រតិបត្តិតាម។

ទោះយ៉ាងណាក៏ដោយកត្តាដែលគួរអោយព្រួយបារម្ភថែមទៀតនោះគឺ ច្បាប់ ឬក្រឹត្យដែលដាក់ថ្វាយព្រះអង្គត្រូវបានសម្រេចរួចហើយ ដោយស្ថាប័ននីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ។ ព្រះមហាក្សត្រគ្រាន់តែឡាយព្រះហស្ថលេខាតែប៉ុណ្ណោះ។ ព្រះអង្គទាំងមិនមានសិទ្ធិបដិសេធមិនឡាយព្រះហស្ថលេខាលើច្បាប់ណាដែលព្រះអង្គមិនសព្វព្រះទ័យ និងរារាំងមិនអោយច្បាប់ណាដែលព្រះអង្គមិនសព្វព្រះទ័យចូលជាការមិនបានឡើយ។ ម្យ៉ាងទៀត តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ "ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ"។ ដូច្នេះព្រះមហាក្សត្រ ពុំអាចចេញសេចក្តីសម្រេចជាបទបញ្ជាបានទេ ទាំងបទបញ្ជាស្វ័យត និងបញ្ជាអនុវត្ត ច្បាប់។ រាល់សេចក្តីសម្រេចធ្វើបទបញ្ជាជាភារកិច្ចរបស់រាជរដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី។ ព្រះមហាក្សត្រ ក្នុងព្រះរាជតួនាទីជាប្រមុខរដ្ឋ ជាអ្នកផ្តល់នីត្យានុកូលភាពដល់រាល់បទបញ្ជា ដែលសម្រេចឡើងដោយគណៈរដ្ឋមន្ត្រី តាមរយៈព្រះហស្ថលេខាលើព្រះរាជក្រឹត្យ ក្នុងលក្ខខ័ណ្ឌនៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសអោយប្រើច្បាប់ ដែលរដ្ឋសភាអនុម័តរួចហើយ និងលើព្រះរាជក្រឹត្យតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។

ក៏ដូចគ្នានឹងករណីនៃអំណាចតែងតាំងដែរ ការដែលព្រះមហាក្សត្រមិនមានអំណាចបដិសេធមិនឡាយព្រះហស្ថលេខាលើច្បាប់ជាការរំលោភលើព្រះរាជកិច្ចរបស់ព្រះអង្គនៅក្រោមមាត្រា៨ នៃ

រដ្ឋធម្មនុញ្ញ។ ឧបមាថា រដ្ឋសភាបានថ្វាយច្បាប់មួយទៅព្រះមហាក្សត្រ ដើម្បីសុំចុះហស្ថលេខា។ ឧបមាទៀតថា ច្បាប់នោះជាច្បាប់កាត់បន្ថយសិទ្ធិ និងសេរីភាពមួយចំនួនរបស់ប្រជាពលរដ្ឋ។ បើសិនព្រះអង្គប្រកាសអោយប្រើច្បាប់នោះ ព្រះអង្គនឹងរំលោភលើព្រះរាជកិច្ចរបស់ព្រះអង្គ ដែលចែងក្នុងមាត្រា៨ នៃរដ្ឋធម្មនុញ្ញ "ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ"។ ហើយឧបមាទៀតថា រដ្ឋសភាថ្វាយច្បាប់មួយទៀតទៅព្រះមហាក្សត្រ ដើម្បីសុំព្រះហស្ថលេខា។ ឧបមាថា ច្បាប់នោះជាច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម។ ហើយការកាត់ទោសនេះជាផលវិបាក នឹងនាំមកនូវការបះបោរបែកបាក់នៅក្នុងរដ្ឋ និងសង្គ្រាម។ បើសិនព្រះមហាក្សត្រឡាយព្រះហស្ថលេខាលើច្បាប់នេះ ព្រះអង្គនឹងរំលោភលើព្រះរាជកិច្ចរបស់ព្រះអង្គ ក្នុងមាត្រា៨ ដដែល វាក្យខ័ណ្ឌទី១ ដែលចែងថា ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។

បន្ថែមលើអំណាចុះហស្ថលេខាប្រកាសប្រើច្បាប់ ព្រះមហាក្សត្រក្នុងព្រះរាជតួនាទី ជាប្រមុខរដ្ឋមាត្រា២៦ ទ្រង់មានអំណាចឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ប៉ុន្តែទ្រង់ប្រទានសច្ចាប័នលើសិទ្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។

# ជំពូក៣

# តួនាទីរបស់ព្រះមហាក្សត្រ

## ៣.១.តួនាទីរបស់ព្រះមហាក្សត្រ

យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩ ចែងថា "ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញកណ្តាលដើម្បីធានាការប្រព្រឹត្តទៅនៃអំណាច សាធារណៈអោយមានភាពទៀងទាត់។"

ព្រះមហាក្សត្រមិនទទួលខុសត្រូវចំពោះសភាជាតិ និងការធ្វើទំនាក់ទំនងដោយព្រះរាជសារ ហើយព្រះរាជសារនេះមិនត្រូវបានគេយកមកពិភាក្សា និងបកស្រាយឡើយ។

ក្នុងន័យនេះ តួនាទីដ៏ខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈអោយមានភាពទៀតទាត់ គឺមានន័យថាជាតួនាទីដែលត្រូវបានផ្តល់អោយព្រះមហាក្សត្រ នូវអំណាចសម្របសម្រួលមួយដ៏សំខាន់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ តួនាទីនេះ គឺដើម្បីធ្វើអន្តរាគមន៍នៅពេលដែលប្រទេសជាតិមានវិបត្តិផ្នែកនយោបាយតានតឹងមិនអាចដោះស្រាយបាន។

## ៣.២.ឋានៈរបស់ព្រះមហាក្សត្រ

ព្រះមហាក្សត្រព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិ សញ្ញាអន្តរជាតិ។

## ៣.៣.ព្រះមហាក្សត្រជាប្រមុខអង្គតុលាការ

រដ្ឋធម្មនុញ្ញបានថ្វាយព្រះមហាក្សត្រនូវឋានៈជាប្រមុខនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមអធិបតេយ្យភាពនៃព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាស្ថាប័នកំពូលនៃអង្គតុលាការដែលមានព្រះមហាក្សត្រជាប្រធាន និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាសមាជិក។ ព្រះមហាក្សត្រ មានភារកិច្ចធានាឯករាជ្យភាពនៃតុលាការដាច់ចេញពីសាខាពីរផ្សេងទៀតនៃរដ្ឋាភិបាល សាខានីតិបញ្ញត្តិ និងសាខានីតិប្រតិបត្តិ។ ចៅក្រមមិនត្រូវទទួលការគាប

សង្កត់ ឬការគំរាមកំហែងពីសំណាក់អំណាចណាមួយឡើយ។ សមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានេះត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដើម្បីជួយព្រះមហាក្សត្រ ក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការធានាវិស័យរបស់ចៅក្រម និងធានាការប្រព្រឹត្តទៅនៃសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា អោយមានដំណើរការកាន់តែប្រសើរ។ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាស្ថាប័នជាន់ខ្ពស់បំផុតនៃតុលាការ ហើយព្រះមហាក្សត្រ ជាប្រមុខនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រក៏ត្រូវជាប្រមុខនៃអង្គតុលាការនៃកម្ពុជាដែរ។ ដោយហេតុថា "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកសម្រេច និងលើកសេចក្តីស្នើរថ្វាយព្រះមហាក្សត្រ អំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់មុខងារ ការដាក់អោយនៅទំនេរ ការដាក់អោយនៅក្របខ័ណ្ឌ ការដកហូត ការងារចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។ ឧត្តមក្រុមប្រឹក្សានៃនេះអោយយោបល់ចំពោះការតំឡើងថ្នាក់ និងការតំឡើងឋានន្តរស័ក្តិអោយចៅក្រម និងព្រះរាជអាជ្ញាទាំងអស់"។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអ្នកលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រចំពោះការតែងតាំង ការផ្លាស់ប្តូរ និងការដកហូតការងារ...។ ក្នុងមុខងារដាក់ទោសវិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវប្រជុំក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ និងក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនចូលរួមការប្រជុំដាក់ទោសវិន័យនេះឡើយ។ យោងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រជាប្រមុខនិមិត្តរូបនៃតុលាការតែប៉ុណ្ណោះ។ ព្រះអង្គទ្រង់ពុំមានអំណាចតែងតាំងតំឡើងបុណ្យស័ក្តិ និងដកហូតបញ្ចុះបុណ្យស័ក្តិចៅក្រមតាមព្រះទ័យព្រះអង្គឡើយ។ ការតែងតាំង និងការដកហូត ធ្វើតាមអ្វីដែលក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរៀបចំថ្វាយ និងសម្រេចរួចហើយ។ ទោះបីដាក់វិន័យចំពោះ ប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការ ក្រុមប្រឹក្សាវិន័យត្រូវស្ថិតនៅក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាងក៏ដោយ ព្រះមហាក្សត្រនៅតែត្រូវបានគេមើលឃើញថា ជាប្រមុខដែលមានអំណាចនិមិត្តរូបប៉ុណ្ណោះនៃតុលាការ។

## ៣.៤.តួនាទីព្រះមហាក្សត្រក្នុងការដឹកនាំប្រទេសជាតិ

ព្រះមហាក្សត្រទ្រង់ជាអ្នកតែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែង ក្នុងមាត្រា១១៩ថ្មី។

ព្រះមហាក្សត្រទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែឱ្យនាយករដ្ឋមន្រ្តី និងគណៈរដ្ឋមន្រ្តីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ។

## ៣.៥.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យច្បាប់

ព្រះមហាក្សត្រទ្រង់ ឡាយព្រហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័ន លើសន្ធិសញ្ញា និងអនុសញ្ញាទាំងនោះក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។

## ៣.៦.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យសេដ្ឋកិច្ច

ព្រះមហាក្សត្រ មានភារកិច្ចលើគ្រប់វិស័យសេដ្ឋកិច្ចដូចជាការអនុវត្តន៍ តាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ ហើយការរៀបចំនេះ និងការព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះត្រូវបានកំណត់ក្នុងច្បាប់។

## ៣.៧.ភារកិច្ចរបស់ព្រះមហាក្សត្រលើវិស័យនយោបាយ

ព្រះរាជាណាចក្រកម្ពុជា អនុវត្តន៍តាមរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ម្យ៉ាងវិញទៀតព្រះមហាក្សត្រមានតួនាទីយ៉ាងសំខាន់ ការពារឯករាជ្យអធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយ បង្រួបបង្រួមជាតិដើម្បីការពារឯកភាពជាតិរក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាពធានាសណ្តាប់ធ្នាប់និងសន្តិសុខ សាធារណៈ។ រដ្ឋយកចិត្តទុកដាក់ជាអទិភាពចំពោះជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមកយើងអាចសន្និដ្ឋានបានថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រង់រាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច។ ថ្វីត្បិតតែទ្រង់មិនកាន់អំណាចដោយផ្ទាល់ ប៉ុន្តែទ្រង់ជាព្រះប្រមុខរដ្ឋ ។ ដូច្នេះ ព្រះអង្គពុំមានអំណាចពិតប្រាកដឡើយ ព្រោះថារាល់ការតែងតាំង ការដកហូត និងឡាយព្រះហស្ថលេខាលើច្បាប់ សន្ធិសញ្ញាផ្សេងៗ គឺត្រូវតែមានការស្នើរសុំពីស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ ។

តួនាទីភារកិច្ចរបស់ព្រះមហាក្សត្រដើម្បីធានានូវអព្យាក្រឹត គឺព្រះមហាក្សត្រត្រូវតែគង់នៅពីលើនយោបាយ។ ម្យ៉ាងវិញទៀត តួនាទីដ៏ខ្ពង់ខ្ពស់ជាអាជ្ញាកណ្ដាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈអោយមានភាពទៀងទាត់ គឺមានន័យថា ជាតួនាទីដែលត្រូវបានផ្ដល់អោយព្រះមហាក្សត្រនូវអំណាចសម្របសម្រួលមួយដ៏សំខាន់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ តួនាទីនេះគឺដើម្បីធ្វើអន្តរាគមន៍ នៅពេលដែលប្រទេសជាតិមានវិបត្តិផ្នែកនយោបាយតានតឹងដែលមិនអាចដោះស្រាយបាន។

សរុបសេចក្ដី ស្របតាមការកំណត់របស់រដ្ឋធម្មនុញ្ញ យើងពិនិត្យឃើញថា ព្រះមហាក្សត្រព្រះអង្គទ្រង់មានព្រះរាជកិច្ច ពីរ យ៉ាងគឺៈ

- **ព្រះរាជកិច្ច ជាអធិបតីៈ** គឺព្រះអង្គជានិមិត្តរូប និងគង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាអធិបតីនៃសមាជជាតិ ។ល។
- **ព្រះរាជកិច្ច ជារដ្ឋបាលៈ** គឺចង់មានន័យថា ព្រះអង្គឡាយព្រះហស្ថលេខាលើច្បាប់ សន្ធិសញ្ញាផ្សេងៗ និងការតែងតាំង ដកហូតជាដើម។

ជាភ័ព្វសំណាងណាស់ សម្រាប់ព្រះរាជាណាចក្រកម្ពុជាយើង ដែលមានព្រះមហាក្សត្រគ្រង់រាជសម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់កូនចៅរបស់ព្រះអង្គ។ កត្តាដែលគួរអោយចាប់អារម្មណ៍ថែមទៀតនោះ គឺព្រះមហាក្សត្រទ្រង់មិនប្រឡូកក្នុងនយោបាយឡើយ ជាកត្តាមួយយ៉ាងពិសេស ពោលគឺដើម្បីបញ្ចៀសផុតពីការធ្វើអោយប៉ះពាល់ដោយចេតនាក្ដី ឬអចេតនាក្ដី ដល់ព្រះកិត្តិនាមព្រះមហាក្សត្រ។

# ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣.............................................បោះពុម្ពឆ្នាំ២០១០

២. Web site: WWW.Car.gov.kh, ម៉ោង១០:00ព្រឹក..........................................២៥/០៦/២០១១

៣. ច្បាប់ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី" ..........................................ឆ្នាំ១៩៩៤

៤. ច្បាប់ស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម" បោះពុម្ពដោយអង្គការប្រជាជាតិ......................................................................................................ឆ្នាំ១៩៩៧